**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨៤/០០៧ /២០០៤
ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦២/០០៤/២០០៤ កបធ.ច
ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៤

# ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤ របស់តំណាងរាស្ត្រចំនួន ១៣ រូប ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីបាតុកម្ម

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា តំណាងរាស្ត្រចំនួន ១៣ រូប បានធ្វើលិខិតមួយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤ មកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីបាតុកម្ម ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃខែឆ្នាំ ដដែល វេលាម៉ោង ១០:០០ ព្រឹក។ តំណាងរាស្ត្រជាម្ចាស់សំណើមានចំនួន ១៣ រូប ដូចនេះ គឺគ្រប់គ្រាន់តាមបទបញ្ញត្តិនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញហើយ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម / ០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ។

-យល់ឃើញថា បាតុកម្ម ជាអំពើប្រព្រឹត្តដោយជនមួយក្រុម សំដែងឱ្យសាធារណជនទាំងពួងឃើញ ឬ ដឹងនូវមនោសញ្ចេតនា គំនិត ឬ ឆន្ទៈណាមួយរបស់ក្រុមខ្លួន ។ សិទ្ធិធ្វើបាតុកម្ម និង សិទ្ធិធ្វើកូដកម្ម ជាសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ប៉ុន្តែប្រជាពលរដ្ឋ ត្រូវប្រើសិទ្ធិនេះ ដោយសន្តិវិធី កុំឱ្យប៉ះពាល់

ដល់សិទ្ធិអ្នកដទៃ ហើយក៏កុំឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ បរិស្ថាន សុខុមាលភាពសាធារណៈ និង សន្តិសុខសង្គម ។ មានតែច្បាប់ទេ ដែលកំណត់ក្របខ័ណ្ឌនៃការធ្វើបាតុកម្ម គឺច្បាប់កំណត់ឱ្យអាជ្ញាធរសាធារណៈ ចាត់វិធានការនានា ដើម្បីធានាសិទ្ធិរបស់បាតុករផង ហើយដើម្បីរក្សាឱ្យបាននូវរបៀបរៀបរយសាធារណៈ បរិស្ថាន សុខុមាលភាព និង សន្តិសុខសង្គមផង ។ មាត្រា ៣៧ នៃរដ្ឋធម្មនុញ្ញ ចែងច្បាស់ថា " *សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។* " ។

-យល់ឃើញថា កាលបើក្របខ័ណ្ឌដែលច្បាប់កំណត់ឱ្យអាជ្ញាធរសាធារណៈ ចាត់វិធានការណាមួយនោះ លែង សមស្របនឹងសភាពការណ៍បច្ចុប្បន្ននៃប្រទេសជាតិ មានតែរដ្ឋសភាទេ ដែលអាចកែប្រែបទបញ្ញត្តិនៃច្បាប់ដែល ពុំសមស្របនោះ ឱ្យសមស្របទៅវិញ ។ បើពុំនោះសោតទេ បទបញ្ញត្តិនៃច្បាប់នោះ នៅតែបន្តមានអានុភាព អនុវត្តដដែល ។ មាត្រា ១៥៨ ថ្មី ( មាត្រា ១៣៩ ចាស់) នៃរដ្ឋធម្មនុញ្ញ ចែងច្បាស់ថា " *ច្បាប់ និង លិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និង ទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និង ដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬ លុបចោល លើកលែងតែបទបញ្ញត្តិណា ដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។* " ។

-យល់ឃើញថា តំណាងរាស្ត្រចំនួន ១៣ រូប ដែលបានស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់បាតុកម្ម ដែល រដ្ឋសភានៃអតីតរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១ បានលើកឡើងថា ខ្លឹមសារក្នុងមាត្រា ខ្លះនៃច្បាប់នេះបានផ្ទុយទៅនឹងស្មារតីមាត្រា ៣៧ នៃរដ្ឋធម្មនុញ្ញ ប៉ុន្តែពុំបានចង្អុលឱ្យចំថា តើបទបញ្ញត្តិនៃ មាត្រាណាមួយ ដែលផ្ទុយនោះទេ ។

-យល់ឃើញថា បើនិយាយអំពីខ្លឹមសារវិញ ច្បាប់ស្តីពីបាតុកម្មដែលអនុម័តដោយរដ្ឋសភាអតីតរដ្ឋកម្ពុជា កាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១ មិនផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីបាតុកម្ម ដែលអនុម័តដោយរដ្ឋសភាអតីតរដ្ឋកម្ពុជា កាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១ ត្រូវបាន ប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃ ក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាច ទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**